ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋលើសហគ្រាស ចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/រកម/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :**

បង្កើតគណៈកម្មាធិការជាតិអវិនិយោគ (National Divestment Committee) របស់រដ្ឋលើសហគ្រាសចំការកៅស៊ូរដ្ឋទាំង៧ ក្រុមហ៊ុនសម្ភារៈកសិកម្ម និង ក្រុមហ៊ុនជលផល ។

**មាត្រា ២ :**

គណៈកម្មាធិការជាតិនេះមានគោលបំណងជំរុញការធ្វើសវនកម្មលើសហគ្រាសចំការកៅស៊ូរដ្ឋក្រុមហ៊ុនសម្ភារៈកសិកម្ម និង ក្រុមហ៊ុនជលផល ដែលមានស្រាប់តាមកម្រិតនិយាមគណនេយ្យអន្តរជាតិដែលអាចទទួលយកបាននិងការត្រួតពិនិត្យសន្និដ្ឋាន និង វាយតម្លៃអំពីស្ថានភាពទូទៅនៃការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនសម្ភារៈកសិកម្ម ក្រុមហ៊ុនជលផល និង អាជីវកម្ម-ផលិតកម្មរបស់ចំការកៅស៊ូ។ បន្ទាប់ពីការធ្វើសវនកម្មរួច

គណៈកម្មាធិការជាតិនេះធ្វើសេចក្ដីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចក្នុងការជ្រើសរើសយករូបភាពណាមួយ នៃការធ្វើអវិនិយោគរបស់រដ្ឋលើសហគ្រាសចំការកៅស៊ូរដ្ឋទាំង ៧ ក្រុមហ៊ុនសម្ភារៈកសិកម្ម និង ក្រុមហ៊ុនជលផល ។

## មាត្រា ៣ :

គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋលើសហគ្រាសចំការកៅស៊ូរដ្ឋ ក្រុមហ៊ុនជលផល និងក្រុមហ៊ុនសម្ភារៈកសិកម្មរួមមានសមាសភាពដូចតទៅ:

១- ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ............................ ជាប្រធាន

២- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ.................................. ជាអនុប្រធាន

៣- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមួយ (០១)រូប ........................................ ជាអនុប្រធាន

៤- តំណាងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មួយ (០១)រូប ................ជាសមាជិក

៥- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មួយ (០១)រូប ..................................ជាសមាជិក

៦- តំណាងក្រសួងពាណិជ្ជកម្ម មួយ(០១)រូប .......................................................ជាសមាជិក

៧- តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ មួយ (០១)រូប ..............................................ជាសមាជិក

ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តាំងមន្ត្រីដែលមានឋានៈយ៉ាងទាបត្រឹមអគ្គនាយកឱ្យចូលរួមធ្វើជាតំណាងក្នុងគណៈកម្មាធិការជាតិនេះ ។

## មាត្រា ៤ :

គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋលើសហគ្រាសចំការកៅស៊ូរដ្ឋ ក្រុមហ៊ុនជលផល និងក្រុមហ៊ុនសម្ភារៈកសិកម្មរួមមានភារៈកិច្ចៈ

- ធានាការធ្វើសវនកម្មទៅតាមសហគ្រាសនីមួយៗ ដោយអនុវត្តតាមកម្រិតនិយាមអន្តរជាតិនិងដោយសវនករ ឬ ក្រុមហ៊ុនសវនកម្មអន្តរជាតិដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចទទួលយកបាន ។
- ធានាការផ្ដល់ជាមុននូវឯកសារសំរាប់ធ្វើសវនកម្មរួមមាន : របាយការណ៍ស្ដីពីស្ថានភាពហិរញ្ញវត្ថុសមស្រប ( ទុនចល័ត និង អចល័ត, ចំណូល និង ចំណាយ, លំហូរសាច់ប្រាក់ ។ល។ ) បញ្ជីមន្ត្រី និយោជិក និងកម្មករ, បញ្ជីទ្រព្យសម្បត្តិអចលនវត្ថុ, ចំណាយលើរំលោះអចលនវត្ថុរបស់សហគ្រាសសាធារណៈនីមួយៗក្នុងឆ្នាំការិយបរិច្ឆេទ ចាប់តាំងពីឆ្នាំ ១៩៩៩ មក ។

- គ្រប់គ្រង និង តាមដានសកម្មភាព និង លទ្ធផលការងាររបស់សវនករ ដែលចុះទៅបំពេញការងារនៅតាមសហគ្រាសសាធារណៈនីមួយៗ ។
- ធ្វើការបញ្ជាក់ និង វាយតម្លៃយន្តការសមស្របចំពោះភាគហ៊ុនរបស់រដ្ឋដែលមាននៅក្នុងសហគ្រាសសាធារណៈនីមួយៗ រួមមានការជម្រះបញ្ជី ការគ្រប់គ្រងលទ្ធកម្ម ការរំលាយបញ្ចូលគ្នា ឬ ការរៀបចំបើកក្រុមហ៊ុនសាធារណៈ ។
- រៀបចំអនុសាសន៍ឱ្យបានខ្លី និង ច្បាស់លាស់ ដើម្បីជូនរាជរដ្ឋាភិបាលអំពីពេលវេលាកំណត់ លំអិតនៃផែនការរំលោះវិនិយោគរបស់រដ្ឋលើសហគ្រាសនីមួយៗ ដោយផ្អែកលើមូលដ្ឋាននៃរបាយការណ៍របស់សវនករ ។
- ផ្តល់ភាពងាយស្រួលក្នុងដំណើការនៃការពិគ្រោះយោបល់ និង ការចរចារជាមួយដៃគូសំខាន់នានាដែលមានការពាក់ពន្ធ័ នៅក្នុងដំណើរការនៃការធ្វើអវិនិយោគរបស់រដ្ឋលើសហគ្រាសនីមួយៗរួមទាំង មន្ត្រីនិយោជិក និង កម្មកររដ្ឋផង ។
- អនុវត្តវិធានការចាំបាច់នានាដើម្បីធានាដល់បុគ្គលិកនិយោជិករដ្ឋមិនឱ្យបាត់បង់ផលប្រយោជន៍ដោយមិនត្រឹមត្រូវក្នុងដំណើការនៃការធ្វើអវិនិយោគរបស់រដ្ឋ ។
- កំណត់នីតិវិធីសំរាប់ការគ្រប់គ្រង និង ការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីដំណើរការធ្វើអវិនិយោគដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។
- ធ្វើរបាយការណ៍ស្តីពីភាពជឿនលឿននៃការធ្វើអវិនិយោគរបស់រដ្ឋ នៅតាមសហគ្រាសនីមួយៗ ដោយទៀងទាត់ ដើម្បីជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**មាត្រា ៥ :**

គណៈកម្មាធិការជាតិនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីស្នាក់ការស្ថិតនៅក្នុងទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋលើសហគ្រាសសាធារណៈមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦ :**

ប្រធានគណៈកម្មាធិការជាតិ មានសិទ្ធិបង្កើតអនុគណៈកម្មាការជំនាញដោយឡែកៗ ដើម្បីជួយគាំទ្រកិច្ចការរបស់គណៈកម្មាធិការជាតិនេះ ។

**មាត្រា ៧ :**

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋលើសហគ្រាសរដ្ឋនេះត្រូវដឹកនាំដោយរដ្ឋលេខាធិការមួយរូប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើជាប្រធានលេខាធិការដ្ឋានក្នុងការដឹកនាំ និង ចាត់ចែងការងារប្រចាំថ្ងៃ ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍មានបុគ្គលិកផ្ទាល់ និងក្រុមការងារមួយចំនួនដែលជាមន្ត្រីមានក្របខ័ណ្ឌស្រាប់។ លេខាធិការដ្ឋានអាចមានអ្នកជំនួយការបរទេសមួយក្រុម ដែលមានជំនាញផ្នែកគណនេយ្យ សេដ្ឋកិច្ច និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការធ្វើអវិនិយោគរបស់រដ្ឋលើសហគ្រាសសាធារណៈ ដើម្បីសម្រួលដល់កិច្ចប្រតិបត្តិការ ។

**មាត្រា ៨ :**

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិមានភារកិច្ច :

- សិក្សាស្រាវជ្រាវ រៀបចំសេចក្តីព្រាង គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និង កម្មវិធីអនុវត្តន៍នៅក្នុងដំណើរការនៃការធ្វើអវិនិយោគរបស់រដ្ឋលើសហគ្រាសសាធារណៈ ដើម្បីដាក់ជូនគណៈកម្មាធិការពិនិត្យ និង សម្រេច ។
- រៀបចំឯកសារនានាចាំបាច់សម្រាប់ធ្វើការដេញថ្លៃជ្រើសរើសក្រុមហ៊ុនសវនកម្ម តាមកម្រិតនិយាមគណនេយ្យអន្តរជាតិ ដើម្បីដាក់ជូនគណៈកម្មាធិការពិនិត្យ និង សម្រេច ។
- រៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារសម្រាប់ឱ្យសវនករបំពេញ និង អនុវត្តឱ្យបានសមស្រប ។
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការ និងសម្របសម្រួលជាមួយក្រុមហ៊ុនសវនកម្ម ឬអន្តរជាតិដែលដេញថ្លៃបាន ដើម្បីរៀបចំផែនការ និង កម្មវិធីអនុវត្តន៍ការងារសវនកម្មនៅតាមចំការកៅស៊ូនីមួយៗ ក្រុមហ៊ុនជលផល និងក្រុមហ៊ុនសម្ភារៈកសិកម្ម ។
- តាមដាន និងរាយការណ៍អំពីភាពរីកចម្រើន នៃសកម្មភាពការងាររបស់សវនករ និង លើកឡើងអំពីការលំបាកនានាដែលកើតឡើង ដាក់ជូនគណៈកម្មាធិការពិនិត្យ និង ដោះស្រាយ ។
- រៀបចំខ្លឹមសារ ឯកសារ និងកម្មវិធីប្រជុំរបស់គណៈកម្មាធិការជាតិ ។ រៀបចំកំណត់ហេតុបូកសរុបលទ្ធផលនៃកិច្ចប្រជុំ និងអនុវត្តរាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ។
- ស្រាវជ្រាវ និងពិនិត្យឯកសាររួមមាន : របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុប្រចាំឆ្នាំ ចលនទ្រព្យ និងអចលនទ្រព្យរបស់សហគ្រាស កិច្ចសន្យា និងឯកសារផ្សេងៗទៀតដែលយល់ថាចាំបាច់ ។
- អនុវត្តការងារផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិប្រគល់ឱ្យ ។

**មាត្រា ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១០ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ខែ ឧសភា ឆ្នាំ២០០៣

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- ឯកសារ-កាលប្បវត្តិ